# គោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រង សំរាម សំណាល់រឹងទីប្រជុំជន







គីន ឃាងលី
អនុប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹង
អគ្គនាយកដ្ឋានគាំពារបរិស្ថាន

# មាតិកា

១.ទីលានចាក់សំរាម
២.លក្ខខណ្ឌក្នុងការជ្រើសរើសទីលាន
៣.ទីលានសាមញ្ញមានការត្រួតពិនិត្យ
    ៣.១ ការរៀបចំទីលាន
    ៣.២ ការរៀបចំបាតទីលាន
    ៣.៣ ការរៀបចំកូនប្រឡាយប្រមូលទឹកសម្អុយ
៤.ទីលានប្រកបដោយអនាម័យ
    ៤.១ការរៀបចំទីលានប្រកបដោយអនាម័យ
    ៤.២ ការរៀបចំបាតទីលាន
    ៤.៣ ការរៀបចំកូនប្រឡាយប្រមូលទឹកសម្អុយ
    ៤.៤ ប្រព័ន្ធប្រមូលឧស្ម័នទីលាន
    ៤.៥ ការត្រួតពិនិត្យនិងអង្កេតតាមដាម
        ៤.៥.១ ពេលដំណើរការទីលាន
        ៤.៥.២ ការគ្រប់គ្រងទីលានបញ្ចប់ និងការគ្រប់គ្រងបន្ត
        ៤.៥.៣ ការត្រួតពិនិត្យគុណភាពទឹកនិងដី

# ១.គោលការណ៍នៃការរៀបចំ និងការគ្រប់គ្រងទីលាន

## ១.១ តម្រូវការទូទៅ

ទីលានចាក់សំរាម សំណល់រឹង គឺជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន បើទោះបីជាមានកម្មវិធីកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែឆ្នៃ ឬការដុតក្នុងឡត្រូវបានអនុវត្តយ៉ាងណាក៏ដោយ។ ទីលានទុកដាក់សំរាម សំណល់រឹង គួរត្រូវប្រើប្រាស់សម្រាប់ទុកដាក់តែសំណល់មិនរលួយ មិនអាចដុតឆេះ និងជាប្រភេទសំណល់ដែលអស់លទ្ធភាពក្នុងការទាញយកធនធាន ឬធ្វើការកែច្នៃបាន។

ទីលានចាក់សំរាម សំណល់រឹង គប្បីត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាផលប៉ះពាល់ដល់គុណភាពបរិស្ថាននិងសុខភាពសាធារណ:។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការសាងសង់និងគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹង គឺដើម្បីបង្កើតឱ្យមានទីតាំងដាក់លាក់ក្នុងការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយសុវត្ថិភាពបរិស្ថាន កាត់បន្ថយការបោះចោលសំរាម សំណល់រឹងរាយប៉ាយតាមផ្លូវសាធារណ: ប្រព័ន្ធបង្ហូរទឹកសាធារណ: និងប្រភពទឹកធម្មជាតិ ក៏ដូចជាលើកកម្ពស់សោភ័ណ្ឌភាពទីប្រជុំជន និងសុខភាពសាធារណ:។

## ២. លក្ខខណ្ឌក្នុងការជ្រើសរើសទីលានចាក់សំរាម

រដ្ឋបាលរាជធានី ក្រុង ត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រ ជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុកការកំណត់ជ្រើសរើសទីកន្លែង សម្រាប់គម្រោងរៀបចំទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវមានការឯកភាពពី រដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ។(អនុក្រឹត្យ១១៣មាត្រា៣៦)

## ២. លក្ខខណ្ឌក្នុងការជ្រើសរើសទីលានចាក់សំរាម(ត)

ទីលានចាក់សំរាម សំណល់រឹងអាចបង្កបញ្ហាស្មុកស្មាញ និងអាចមានផលប៉ះពាល់ច្រើនទៅលើគុណភាពបរិស្ថាន ទេសចរណ៍ សុខមាលភាពប្រជាជន ក៏ដូចដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រសិនបើមិនត្រូវបានរៀបចំត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។ ដូចនេះ ដើម្បីជៀសវាងបញ្ហាប្រឈមនៅថ្ងៃមុខជាយថាហេតុ មុននឹងសម្រេចផ្តល់ទីតាំងសាងសង់ទីលានចាក់សំរាម សំណល់រឹង តម្រូវឱ្យមានការពិនិត្យលក្ខខណ្ឌមូលដ្ឋានមួយចំនួនដូចតទៅ ៖

- ស្ថិតនៅលើទីតាំងដែលមិនមានការលិចទឹក និងត្រូវមានផ្លូវចេញចូលបានគ្រប់រដូវ
- ជាប្រភេទដីរិចរិលពុំសូវមានជីជាតិសម្រាប់ដំណាំកសិកម្ម (តម្លៃទាប)

## ២.លក្ខខណ្ឌក្នុងការជ្រើសរើសទីលានចាក់សំរាម(ត)



## ៣.ទីលានសាមញ្ញមានការត្រួតពិនិត្យ

តម្រូវការសម្រាប់សាងសង់ ការគ្រប់គ្រងទីលានមាននិងការត្រួតពិនិត្យ នៅមានកម្រិតមួយទាប ប៉ុន្តែក៏តម្រូវឲ្យមានការត្រួតពិនិត្យនិងការមានអនុញ្ញាតត្រឹមត្រូវ (រូបភាពទី១) ។

**៣.១ ការរៀបចំទីលាន**

- មានរបង មានទំនប់ព័ទ្ធជុំវិញ
- មានដាំដើមឈើធ្វើជាតំបន់ទ្រនាប់
- មានរោងយាមនៅច្រកចូលទីលាន និងជញ្ជីងថ្លឹងសំរាមចូលទីលាន
- មានឃ្លាំងសំណល់កែច្នៃ ឃ្លាំងសម្ភារ រោងជាង បន្ទប់ទឹក សម្ភារការពារសុវត្ថិភាព ឧបករណ៍ពន្លត់អគ្គីភ័យ និងបញ្ជីគ្រប់គ្រងលើអ្នករើសសំរាម

– ប្រព័ន្ធផ្លូវសម្រាប់ដឹកជញ្ជូនសំរាម សំណល់រឹងចូលទៅកាន់ទីលាន រហូតដល់កន្លែងចាក់សំណល់ ដែលអាចប្រើប្រាស់បានគ្រប់រដូវ



*រូបភាពទី១៖ ទីលានសាមញ្ញមានការត្រួតពិនិត្យ*

### ៣.២ ការរៀបចំបាតទីលាន

– លើកទំនប់ឲ្យមានកំពស់ >= ១ម៉ែត្រ ខ្ពស់ជាងបរិវេណជុំវិញ ហើយត្រូវរៀបចំក្រាលបាតទីលាន ដោយមានជំរាល >= ២%ទៅរកប្រឡាយប្រមូលទឹកសម្អុយ

– បាតរណ្ដៅត្រូវចាក់ដីឥដ្ឋកិនបង្ហាប់ឱ្យបានកម្រាស់ >= ១ម៉ែត្រ ដើម្បីការពារគុណភាពទឹកក្រោមដី

– បាតអណ្ដូងលូ ឬបាតអាងស្តុកទឹកសម្អុយដែលជ្រៅបំផុតត្រូវតែមានកម្រិត >= ៣ម៉ែត្រ ធៀបទៅនឹងកម្ពស់អតិបរមានៃកម្រិតកម្ពស់ទឹកក្រោមដី ក្នុងល័ក្ខខ័ណ្ឌដែលល្បឿនជម្រាបទឹករបស់ដី

k ≤ ១x១០$^{-៧}$ស.ម/១វិនាទី




*រូបភាពទី២៖ ពំនុះកាត់បង្ហាញពីការរៀបចំទីលានសាមញ្ញ មានការត្រួតពិនិត្យ*

## ៣.៣ ការរៀបចំកូនប្រឡាយប្រមូលទឹកសម្អុយ

ការរៀបចំប្រឡាយអាចប្រើសម្ភារដូចជា ៖

- សម្បកកង់ឡានចាស់ៗ (រូបទី៣)
- ឬស្សី(រូបទី៣)
- ថ្ម ១ x ២ (គ្រួស) និង ៤ x ៦(រូបទី៤)







*រូបភាពទី៣៖ ការរៀបចំប្រឡាយប្រមូលទឹកសម្អុយទីលាន*
*(សម្បកកង់ឡានចាស់ៗ ឬ ដើមឫស្សី*




*រូបភាពទី៤ ៖ ការរៀបចំប្រឡាយប្រមូលទឹកសម្អុយទីលាន*
*(ថ្ម ១ x ២ (គ្រួស) និង ៤ x ៦*

## សង្ខេបដំណើរការទីលានសាមញ្ញមានការត្រួតពិនិត្យ[1]




## ៤.ទីលានចាក់សំរាមប្រកបដោយអនាម័យ

ទីលានប្រកបដោយអនាម័យគឺជាទីលានដែលបានបំពាក់នូវ បច្ចេកទេសខ្ពស់ សម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជន(ដែលមិនមានលទ្ធភាពក្នុងការទាញយកធនធាន ឬកែច្នៃ) ប្រកបដោយសុវត្ថិភាពបរិស្ថាន មិនបង្កការរំខាន ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបង្ការបាននូវហានិភ័យផ្សេងៗ ចាប់តាំងពីពេលដំណើរការសាងសង់ ពេលដំណើរការ និងក្រោយពេលបញ្ចប់ការប្រើប្រាស់។

## ៤.១ ការរៀបចំទីលានប្រកបដោយអនាម័យ

- រៀបចំរបងព័ទ្ធជុំវិញ
- ដាំដើមឈើធ្វើជាតំបន់ទ្រនាប់
- លើកទំនប់ខ្ពស់ជាងបរិវេណដីជុំវិញយ៉ាងតិច១ម
- រៀបប្រព័ន្ធផ្លូវសម្រាប់ដឹកជញ្ជូនសំរាម
- សង់ការិយាល័យគ្រប់គ្រង ប៉ុស្តិ៍ត្រួតពិនិត្យនៅក្បែរផ្លូវចូលទីលាន និងជញ្ជីងថ្លឹងសំរាម ឃ្លាំងសំណល់កែច្នៃ ឃ្លាំងសម្ភារ រោងជាង បន្ទប់ទឹក មានមធ្យោបាយការពារសុវត្ថិភាព ឧបករណ៍ពន្លត់អគ្គីភ័យ និងកន្លែងលាងរថយន្តដឹកសំរាម
- រៀបចំការញែកសំណល់ដែលអាចកែច្នៃបានជាប្រព័ន្ធ
- ចាក់សំរាម សំណល់រឹងទៅតាមគន្លងដែលបានបែងចែករួច



*រូបភាពទី៥៖ ទីលានចាក់សំរាមប្រកបដោយអនាម័យ*













## ៤.២ ការរៀបចំបាតទីលាន

- ស្រទាប់ទីមួយ ដីឥដ្ឋបង្ហាប់មានកម្រាស់ >= ១ម៉ែត្រ កម្ពស់ខ្ពស់ជាងកម្រិតកម្ពស់អតិបរមានៃទឹកក្រោមដី >= ៣ម៉ែត្រ ក្នុងល័ក្ខខ័ណ្ឌដែលល្បឿនជម្រាបទឹករបស់ដីធម្មជាតិខាងក្រោមស្រទាប់នេះ មានកម្រិត <= ១x១០-៧ស.ម/១វិនាទី។ ជម្រាលស្រទាប់បាតត្រូវមានកម្រិត >= ៣% ទៅរកប្រឡាយប្រមូលទឹកសម្អុយ
- ស្រទាប់ទីពីរ ជាស្រទាប់កៅស៊ូការពារជម្រាបទឹក FML-HDPE (Flexible Membrane Liner-High Density Polyethylene)
- ស្រទាប់ទីបី ជាស្រទាប់ចម្រោះដែលមានប្រព័ន្ធប្រឡាយប្រមូលទឹកសម្អុយ និងប្រព័ន្ធប្រមូលជីវឧស្ម័នទីលាន




*រូបភាពទី៦៖ ការរៀបចំបាតទីលានចាក់សំរាម ប្រកបដោយអនាម័យ*

## ៤.៣ ការរៀបចំភ្លូនប្រឡាយប្រមូលទឹកសម្អុយ

ការរៀបចំប្រព័ន្ធប្រឡាយប្រមូលទឹកសម្អុយសម្រាប់ទីលានប្រភេទនេះ មានលក្ខណៈដូចគ្នាទៅនឹងការរៀបចំសម្រាប់ទីលានសាមញ្ញមានការត្រួតពិនិត្យ។

## ៤.៤ ប្រព័ន្ធប្រមូលឧស្ម័នទីលាន

ការរៀបចំមានវិធីច្រើនយ៉ាងខាងក្រោមជាឧទា. មួយក្នុងការរៀបចំដែលមានលក្ខណៈសាមញ្ញនិងចំនាយទុនតិច (រូបទី៧ ទី៨)។




*រូបភាពទី៧៖ ប្រព័ន្ធប្រមូលឧស្ម័នពេលទីលានកំពុងដំណើរការ*




*រូបភាពទី៨៖ ប្រព័ន្ធប្រមូលឧស្ម័នពេលបិទរណ្តៅនីមួយៗ*

## ៤.៥ ការត្រួតពិនិត្យនិងអង្កេតតាមដាន

### ៤.៥.១ ពេលដំណើរការទីលាន

- ត្រួតពិនិត្យបរិមាណ និងសមាសធាតុសំណល់
- ត្រួតពិនិត្យគុណភាពទឹកក្រោមដី
- ត្រួតពិនិត្យគុណភាពសំណល់រាវដែលបញ្ចេញពីអាងប្រព្រឹត្តិកម្ម ទីលានជាប្រចាំ
- ត្រួតពិនិត្យការចាក់សំណល់ និងការចាក់ដីគ្របសំរាម សំណល់រឹង និងការបង្ហាប់កម្រាស់០.១៥-០.២ម ជាប្រចាំ (សម្រាប់ទីលានប្រកប ដោយអនាម័យ)




*រូបភាពទី៩ ៖ការប្រតិបត្តិទីលានប្រកបដោយអនាម័យ*

### ៤.៥.២ ការគ្រប់គ្រងទីលានបញ្ចប់ និងការគ្រប់គ្រងបន្ត(ត)

- ត្រូវកិនបង្ហាប់សំណល់ដែលចាក់ក្រោយគេនៅលើទីលាន
- ក្រាលកៅស៊ូការពារជម្រាប (FML-HDPE) )
- រៀបស្រទាប់ចម្រោះដើម្បីប្រមូលទឹកដែលជ្រាបពីស្រទាប់លើ ទៅប្រឡាយរំដោះទឹកភ្លៀង
- លុបដីពីលើដោយកិនបង្ហាប់ឲ្យបានកំរាស់ >=១,៥ ម៉ែត្រ រាងខ្នងអណ្តើក ដោយមានមុំជម្រាល >= ៤%
- ជីកប្រឡាយនៅចុងជម្រាលសង្ខាងនៃគម្របទីលានដើម្បីរំដោះទឹកភ្លៀង
- ត្រួតពិនិត្យ ការហូរច្រោះដី ប្រព័ន្ធបង្ហូរទឹកសម្អុយ និងឧស្ម័នទីលាន រហូតដល់មានការបញ្ជាក់ច្បាស់លាស់ថា មិនមានការប៉ះពាល់ដល់បរិស្ថាន។

### ៤.៥.២ ការគ្រប់គ្រងទីលានបញ្ចប់ និងការគ្រប់គ្រងបន្ត (ត)

- ឧស្ម័នដែលលើសត្រូវដុតចោល ជៀសវាងសាយភាយបំពុលបរិស្ថាន ឬការលើសសម្ពាធបង្កការផ្ទុះ
- ថែរក្សារបងព័ទ្ធជុំវិញទីលានឲ្យបានត្រឹមត្រូវ បើខូចត្រូវធ្វើការជួសជុលឡើងវិញ
- ដាំស្មៅ ឬរុក្ខជាតិពីលើដីដែលគ្របរួច ដើម្បីការពារការជ្រាបទឹកភ្លៀង និងរិចរិល។ ការជ្រើសរើសរុក្ខជាតិដាំពីលើទីលានចាក់ចោលសំរាមសំណល់រឹង គួរតែជាប្រភេទរុក្ខជាតិដែលមានអាយុច្រើនឆ្នាំ អាចមានភាពធន់ទៅនឹងគ្រោះរាំងស្ងួតសីតុណ្ហភាពខ្ពស់ និងអាចអនុញ្ញាតឱ្យរុក្ខជាតិរីកលូតលាស់បាន
- ត្រូវមានយន្តការគ្រប់គ្រងនិងតាមដានបន្តអំពីគុណភាពទឹក ដី និងខ្យល់
- គួររៀបចំទីលានដែលបញ្ចប់ការប្រើប្រាស់ទៅជាសួនកំសាន្ត ជាដើម




*រូបភាពទី១០ ៖ការរៀបចំបិទ ទីលាននិងការគ្រប់គ្រងបន្ត*

## ៤.៥.៣ ការត្រួតពិនិត្យគុណភាពទឹកនិងដី

- ត្រួតពិនិត្យតាមដានគុណភាពទឹកក្រោមដី គួរត្រូវបានអនុវត្តជាប្រចាំ ដោយត្រូវយកសំណាកទៅវិភាគ>=២ ដង /ឆ្នាំ នៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ឬមន្ទីរពិសោធន៍ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ

- អ្នកគ្រប់គ្រងទីលាន ត្រូវមានភារកិច្ចរាយការណ៍ដល់ស្ថាប័នបរិស្ថាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ នូវរាល់ផលប៉ះពាល់បរិស្ថានដែលបាន និងអាចកើតមានឡើង

- ការប្រើប្រាស់ទឹកក្រោមដីនៅក្នុង និងជុំវិញទីលាន គឺត្រូវគោរពតាមស្តង់ដារ គុណភាពទឹក។ Landfill Work




*រូបភាពទី១០ ៖ការរៀបចំអណ្តូងសម្រាប់ត្រួតពិនិត្យគុណភាពទឹកក្នុងដី*

## សង្ខេបដំណើរការប្រតិបត្តទីលានប្រកបដោយអនាម័យ




## សូមអរគុណ!

